# ព្រឹត្តិបត្រប្រចាំត្រីមាស

លេខទី៦

ខែកញ្ញា ឆ្នាំ២០១៤




ការថតរូបជុំគ្នានៃក្រុមបច្ចេកទេសប្រព័ន្ធធានាសុវត្ថិភាព និងក្រុមបច្ចេកទេសគម្រោងគំរូ (រូបភាព៖ RTS)

## ទស្សនកិច្ចនៅមូលដ្ឋាន និងកិច្ចប្រជុំរបស់ក្រុមការងារបច្ចេកទេសនៃប្រព័ន្ធធានាសុវត្ថិភាព និងគម្រោងគំរូរេដបូក នៅខេត្តមណ្ឌលគិរី

ក្រុមការងារលេខាធិការដ្ឋានរេដបូកកម្ពុជា បានរៀបចំទស្សនកិច្ចមូលដ្ឋានមួយ និងកិច្ចប្រជុំលើកទី៣ របស់ក្រុមការងារនៃប្រព័ន្ធធានាសុវត្ថិភាព និងគម្រោងគំរូរេដបូក នៅខេត្តមណ្ឌលគិរី ពីថ្ងៃទី២៨ ដល់ ទី៣១ ខែឧសភា ឆ្នាំ២០០៤។

ដំណើរទស្សនកិច្ចនៅមូលដ្ឋាននេះ ត្រូវបានដឹកនាំដោយលោក ឈុន ដឺលុច (ពីរដ្ឋបាលព្រៃឈើ) និងលោក ងួន ភក្តី (ពីសាកលវិទ្យាល័យភ្លាក/សាកលវិទ្យាល័យភូមិន្ទភ្នំពេញ)។ រដ្ឋបាលព្រៃឈើ, ខណ្ឌរដ្ឋបាលព្រៃឈើមណ្ឌលគិរី, មន្ត្រីរដ្ឋបាលព្រៃឈើប្រចាំនៅតំបន់អភិរក្សជីវចម្រុះនៅសីមា, ការិយាល័យទីប្រឹក្សាបច្ចេកទេសប្រចាំរដ្ឋបាលព្រៃឈើ, អង្គការអភិរក្សសត្វព្រៃ (WCS) និងអ្នកភូមិអណ្តូងក្រឡឹង ដែលបានផ្តល់ការគាំទ្ររបស់ពួកគាត់។ ទស្សនកិច្ចនេះ មានអ្នកចូលរួមចំនួន ២៥នាក់ រួមទាំងតំណាងមកពីក្រសួងដែលជាសមាជិកនៃក្រុមការងាររេដបូកកម្ពុជា និងបុគ្គលិកពី UNDP ។

គោលបំណងរបស់ក្រុមបច្ចេកទេសប្រព័ន្ធធានាសុវត្ថិភាព គឺដើម្បី៖ ១) ពិភាក្សាអំពីការបង្កើតគ្រោង រចនាសម្ព័ន្ធ និងលទ្ធផលនៃសេចក្តីព្រាងរបាយការណ៍វាយតម្លៃលក្ខខណ្ឌតម្រូវអន្តរជាតិ លើប្រព័ន្ធធានាសុវត្ថិភាព និងគោលនយោបាយដែលមានស្រាប់ ព្រមទាំងច្បាប់និងបទប្បញ្ញត្តិនៅក្នុងប្រទេសកម្ពុជា, ២) រៀបចំនិងចែកការងារទទួលខុសត្រូវក្នុងចំណោមសមាជិកក្រុម សម្រាប់ការរៀបចំសកម្មភាពទាំងឡាយនាពេលខាងមុខ លើការបង្កើតវិធីសាស្ត្រប្រព័ន្ធធានាសុវត្ថិភាពជាតិ ដែលនឹងជាផ្នែកមួយនៃយុទ្ធសាស្ត្រជាតិរេដបូកកម្ពុជា និងសកម្មភាពដំណើរទស្សនកិច្ចដែលបានធ្វើនាពេលថ្មីៗនេះ ដោយអាជ្ញាធរមូលដ្ឋាន និងអ្នកគាំទ្ររបស់គម្រោង ជាពិសេសអង្គការ WCS ។

គោលបំណងសំខាន់ៗ សម្រាប់ក្រុមបច្ចេកទេសគម្រោងគំរូ គឺដើម្បីឲ្យសមាជិកក្រុម មានភាពថ្មីកជាមួយនឹងទីតាំងគម្រោងគំរូមួយនៃគម្រោងគំរូរេដបូកដែលបានបង្កើតឡើងនៅកម្ពុជា សម្រាប់ពិភាក្សាលម្អិតនាពេលអនាគតរបស់ពួកគេ។ ដំណើរទស្សនកិច្ចនៅមូលដ្ឋាននេះ មានសមាសធាតុបីសំខាន់ៗ៖ ១) ប្រជុំជាមួយអង្គការ WCS ដើម្បីរៀនសូត្រ អំពីសកម្មភាពសាកល្បងនៅទីតាំងគម្រោងគំរូរេដបូកនៅសីមា, ២) ដំណើរទស្សនកិច្ចនៅមូលដ្ឋានមួយទៅទីតាំងគម្រោងគំរូរេដបូកនៅអណ្តូងក្រឡឹង និង ៣) កិច្ចប្រជុំស្តីពីគម្រោងគំរូ ដើម្បីរៀបចំផែនការសម្រាប់សកម្មភាពនាពេលអនាគត។

*សម្រាប់ព័ត៌មានបន្ថែមសូមទំនាក់ទំនង លោក ឈុន ដឺលុច និងលោក ងួន ភក្តី*

**មាតិកា**


◊ អំពី NTFP-EP ............ ២
◊ ព្រឹត្តិការណ៍នាពេលខាងមុខ ............ ២
◊ បច្ចុប្បន្នភាពពីកិច្ចចរចាក្នុង UNFCCC ............ ៣
◊ កម្រងសិក្ខាសាលាស្តីពី ការប្រែប្រួលអាកាសធាតុ........... ៤

# តើនរណាខ្លះអនុវត្តរេដបូកកម្ពុជា?


*ការប្រជុំបណ្តាញរបស់សហគមន៍ជនជាតិដើមភាគតិចនៅខេត្តព្រះវិហារ (រូបភាព៖ NTFP-EP)*

## អង្គការ ផ្លាស់កម្មវិធីអនុផលព្រៃឈើប្រចាំអាស៊ី និងអាស៊ីខាងកើត (NTFP-EP)

អង្គការ NTFP-EP គឺជាបណ្តាញសហការមួយ ដែលមានអង្គការមិនមែនរដ្ឋាភិបាល(NGOs) និងអង្គការសហគមន៍ (CBOs) ជាង ៦០ នៅភាគខាងត្បូងអាស៊ី និងអាស៊ីអាគ្នេយ៍ ដែលធ្វើការជាមួយសហគមន៍ព្រៃឈើ ដើម្បីពង្រឹងសមត្ថភាពរបស់ពួកគេក្នុងការគ្រប់គ្រងធនធានព្រៃឈើ និងធនធានធម្មជាតិប្រកបដោយនិរន្តភាព។ NTFP-EP ត្រូវបានបង្កើតឡើងជាផ្លូវការនៅថ្ងៃទី១៣ ខែមករា ឆ្នាំ២០០៤ នៅទីក្រុងម៉ានីលប្រទេសហ្វីលីពីន។

នៅកម្ពុជា NTFP-EP គឺបានចាប់ផ្តើមសកម្មភាពនៅខែមិថុនា ឆ្នាំ២០០៨ ដែលបានចុះបញ្ជីត្រឹមត្រូវជាមួយក្រសួងការបរទេសជាអង្គការក្រៅរដ្ឋាភិបាលអន្តរជាតិ។ អង្គការ NTFP-EP កម្ពុជា បាន និងកំពុងធ្វើការងារលើផ្នែករេដបូក ក្នុងភាពជាដៃគូជាមួយនឹងអង្គការកតិកាសញ្ញាជនជាតិដើមភាគតិចអាស៊ាន (AIPP) និងអង្គការវេទិកាមិនមែនរដ្ឋាភិបាលស្តីពីកម្ពុជា(NGOF)ចាប់តាំងពីឆ្នាំ២០១១ មក។ អង្គការ NTFP-EP កំពុងដើរតួនាទីយ៉ាងសំខាន់ក្នុងការលើកកម្ពស់ដំណើការចូលរួមរបស់អ្នកពាក់ព័ន្ធចម្រុះក្នុងវិស័យព្រៃឈើសង្គម និងរេដបូក ព្រមទាំងការចូលរួម និងធ្វើជាតំណាងរបស់សង្គមស៊ីវិល និងជនជាតិដើមភាគតិចនៅក្នុងរេដបូក។ លើសពីនេះទៀត អង្គការ NTFP-EP សម្របសម្រួលឲ្យមានឱកាសសម្រាប់លើកកម្ពស់ការយល់ដឹង និងការកសាងសមត្ថភាពដល់អង្គការសង្គមស៊ីវិល និងក្រុមជនជាតិដើមភាគតិចអំពីរេដបូក តាមរយៈឯកសារសង្ខេបសៀវភៅបណ្តុះបណ្តាលនិងផ្ទាំងរូបភាពព័ត៌មាន ជាភាសាក្នុងស្រុក និងភាសាជនជាតិដើមភាគតិច។ NTFP-EP ក៏បានសហការរៀបចំ និងសម្រួលវគ្គបណ្តុះបណ្តាល សិក្ខាសាលា និងកិច្ចប្រជុំពិភាក្សាជាមួយដៃគូបណ្តាញនៅថ្នាក់ជាតិ និងថ្នាក់មូលដ្ឋាន។

*សម្រាប់ព័ត៌មានលម្អិត សូមស្វែងរកនៅក្នុងគេហទំព័រ៖*
*http://www.ntfp.org/*
*http://www.cambodia-redd.org/category/ngo-partners/ntfp-ep#sthash.w6H1Jcds.dpuf*




## ព្រឹត្តិការណ៍នាពេលខាងមុខ

**កិច្ចប្រជុំស្តីពីការរៀបចំរបស់កម្ពុជាដើម្បីចូលរួមក្របខ័ណ្ឌការងារវ៉ាស័រ** (នៅសប្តាហ៍ទី១នៃខែកញ្ញា ឆ្នាំ២០១៤)

កិច្ចប្រជុំនេះគឺដើម្បីឲ្យប្រទេសកម្ពុជាត្រៀមជាស្រេចសម្រាប់ការអនុវត្តរេដបូកលើការទូទាត់ផ្អែកតាមលទ្ធផល តាមរយៈក្របខ័ណ្ឌការងាររេដបូករបស់ UNFCCC ។

**ទស្សនកិច្ចសិក្សារបស់បណ្តាញសង្គមស៊ីវិលទៅខេត្តឧត្តរមានជ័យ (នៅចុងខែសីហា ២០១៤)**

ទស្សនកិច្ចសិក្សានេះ នឹងបង្កើនសមត្ថភាពសម្រាប់សង្គមស៊ីវិលដើម្បីចូលរួមពេញលេញ និងឲ្យមានប្រសិទ្ធិភាព ក្នុងការអភិវឌ្ឍ និងការអនុវត្តយុទ្ធសាស្រ្តជាតិរេដបូកនាពេលអនាគត។

**ការសិក្សាបន្តលើយន្តការមូលនិធិជាតិរេដបូក (ខែកញ្ញា ឆ្នាំ២០១៤)**

ទីប្រឹក្សាមួយក្រុម នឹងបន្តធ្វើការងារលើការបង្កើតសំណើសម្រាប់មូលនិធិជាតិរេដបូក ដើម្បីទទួលបាននូវការទូទាត់ផ្អែកតាមលទ្ធផល។

**សិក្ខាសាលាជាតិស្តីពី ប្រព័ន្ធធានាសុវត្ថិភាព (ខែកញ្ញា ឆ្នាំ២០១៤)**

សិក្ខាសាលានេះ នឹងពិភាក្សាទៅលើការបង្កើតប្រព័ន្ធធានាសុវត្ថិភាពជាតិមួយ ដែលសមស្របសម្រាប់ប្រទេសកម្ពុជា។

**ការបន្តបង្កើតយន្តការដោះស្រាយទំនាស់រេដបូក (ខែតុលា ឆ្នាំ២០១៤)**

ទីប្រឹក្សាមួយក្រុម នឹងបន្តធ្វើការសិក្សាទៅលើថាតើយន្តការដោះស្រាយទំនាស់ទាក់ទងរេដបូកនៅកម្ពុជា នឹងអាចរៀបចំដោះស្រាយឲ្យមានប្រសិទ្ធភាពដោយរបៀបណា។

### ព័ត៌មានទំនាក់ទំនងសមាជិករេដបូកនៅកម្ពុជា

ប្រធានក្រុមការងាររេដបូក៖ **បណ្ឌិត ជា សំអាង**
- ◊ អ៊ីម៉ែល៖ samangfa@gmail.com

អនុប្រធានក្រុមការងាររេដបូក៖ **លោក គឹម ណុង**
- ◊ អ៊ីម៉ែល៖ kimnongmoe@yahoo.com

ប្រធានលេខាធិការដ្ឋានរេដបូក៖ **លោក ឃុន វឌ្ឍនា**
- ◊ អ៊ីម៉ែល៖ vathana.khun@gmail.com

អនុប្រធានលេខាធិការដ្ឋានរេដបូក៖ **លោក អ៊ុយ កាម៉ាល់**
- ◊ អ៊ីម៉ែល៖ kamaluy@yahoo.com

អ្នកសម្របសម្រួលកម្មវិធីរេដបូក៖ **លោក លន់ គឹមហ៊ី**
- ◊ អ៊ីម៉ែល៖ kimhy.lun@undp.org

មន្ត្រីផ្នែកទំនាក់ទំនងកម្មវិធីរេដបូក៖ **កញ្ញា ធី ហៀង**
- ◊ អ៊ីម៉ែល៖ heang.thy@undp.org

ប្រធានក្រុមប្រឹក្សាយោបល់រេដបូក៖ **លោកបណ្ឌិត សៀក សុផាត**
- ◊ អ៊ីម៉ែល៖ seak.sophat@rupp.edu.kh

អនុប្រធានក្រុមប្រឹក្សាយោបល់រេដបូក៖ **លោក សារ ថ្លៃ**
- ◊ អ៊ីម៉ែល៖ sathlay@yahoo.com

# ស្វែងយល់អំពីរេដបូក




## បច្ចុប្បន្នភាពពីកិច្ចចរចាក្នុង អនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិ ស្តីពី ការប្រែប្រួលអាកាសធាតុ នៅទីក្រុងប៊ែរឡាំង ប្រទេសអាល្លឺម៉ង់ (ថ្ងៃទី៥-១១ ខែមិថុនា ឆ្នាំ២០១៤)

សន្និសីទកំពូលនៃបណ្តាប្រទេសជាសមាជិកអនុសញ្ញា លើកទី១៩ (COP19) នៅទីក្រុងវ៉ាសូវី កាលពីឆ្នាំមុន បានសម្រេចនូវលទ្ធផលដ៏សំខាន់មួយសម្រាប់រេដបូក ជាមួយនឹងការសម្រេចចិត្តចំនួនប្រាំពីរ សម្រាប់បណ្តាប្រទេសដែលចូលរួមក្នុងកម្មវិធីរេដបូក ដើម្បីយល់ដឹងឱ្យបានប្រាកដ ថាអ្វីដែលត្រូវបានគេរំពឹងទុកពីបណ្តាប្រទេសទាំងនោះ នៅក្នុងការអនុវត្តគោលការណ៍រេដបូកដោយផ្អែកតាមលទ្ធផល។

ទោះយ៉ាងណា កិច្ចប្រជុំនេះមិនបានសម្រេចបញ្ចប់លើការចរចារបស់ UNFCCC អំពីរេដបូកនោះទេ។ វានៅតែត្រូវការចាំបាច់ក្នុងការបញ្ជាក់ឲ្យច្បាស់លាស់អំពី ការផ្តល់ហិរញ្ញប្បទាននៃលទ្ធផលរេដបូក។ ជម្រើសមួយចំនួននៅតែត្រូវការពិភាក្សារួមមានៈការផ្តល់ហិរញ្ញប្បទានតាមរយៈមូលនិធិអាកាសធាតុបៃតងនិង/ឬទីផ្សារកាបូនឬក៏តាមរយៈវិធីសាស្រ្តផ្សេងទៀត។ តាមរយៈការពិភាក្សាពីមុនៗមក បណ្តាប្រទេសទាំងនោះ ក៏បានសម្រេចចិត្តធ្វើការលើបញ្ហាវិធីសាស្រ្តដែលទាក់ទងនឹងផលប្រយោជន៍មិនមែនជាកាបូន ដែលបានមកពីការអនុវត្តសកម្មភាពរេដបូក និងដើម្បីពិចារណាថាតើវិធីសាស្រ្តមិនផ្អែកលើទីផ្សារ ដូចជាវិធីសាស្រ្តកាត់បន្ថយនិងបន្សាំរួមគ្នា អាចត្រូវបានបង្កើតឡើង។ ប្រធានបទទាំងពីរនេះ ត្រូវបានគេផ្តោតជាសំខាន់នៅក្នុងកិច្ចប្រជុំរបស់ UNFCCC ក្នុងឆ្នាំនេះដែលបានធ្វើរៀបចំឡើងនៅទីក្រុងប៊ែរឡាំង ប្រទេសអាល្លឺម៉ង់។

ទោះជាមានជំនួបជាច្រើនក៏ដោយ បណ្តាប្រទេសទាំងនោះមិនបានសម្រេចយល់ព្រមទៅលើលទ្ធផលសំខាន់ណាមួយនៅឡើយទេ។

**វិធីសាស្រ្តមិនផ្អែកលើទីផ្សារ៖** ប្រទេសភាគច្រើនគិតថាគំរូបែបបទបច្ចុប្បន្នទាំងនេះ គឺក៏អាចអនុវត្តបានសម្រាប់វិធីសាស្រ្តមិនផ្អែកលើទីផ្សារ។ ភាពខុសគ្នាតែមួយគត់ គឺនៅត្រង់ថាតើ ការផ្តល់ហិរញ្ញប្បទាននឹងបានមកពីប្រភពណា។ ស្របពេលជាមួយគ្នានេះ មានសំណើជាក់លាក់មួយពីប្រទេសបូលីវី សម្រាប់វិធីសាស្រ្តរួមបញ្ចូលការបន្សាំ/ការកាត់បន្ថយ ដែលមិនមែនវិធីសាស្រ្តផ្អែកតាមលទ្ធផល។ ប្រទេសបូលីវី ហៅវាថាជាជម្រើសបម្រុងមួយចំពោះរេដបូក។ បណ្តាប្រទេសភាគច្រើនបានគិតថា នេះជាការល្អប្រសិនបើពួកគេនឹងមានការផ្តោតការយកចិត្តទុកដាក់ជាក់លាក់ទៅលើការបន្សាំ ប៉ុន្តែកុំគិតថាវាគឺជាតម្រូវការណាមួយ ដើម្បីបង្កើតច្បាប់អន្តរជាតិសម្រាប់សំណើនេះ។ ប្រធានបទនេះ នឹងត្រូវដាក់បញ្ចូលក្នុងរបៀបវារៈម្តងទៀត ក្នុងកិច្ចប្រជុំ Subsidiary Body for Scientific and Technological Advice (SBSTA) 41 នៅទីក្រុងលីម៉ា ប្រទេសពៀរូ ក្នុងឆ្នាំនេះ។

**ផលប្រយោជន៍ដែលមិនមែនជាកាបូន៖** ជាទូទៅប្រទេសទាំងអស់យល់ឃើញថា ផលប្រយោជន៍ដែលមិនមែនជាកាបូន គឺមានសារៈសំខាន់។ អ្នកខ្លះយល់ថា វាជាបញ្ហាជាតិមួយ និងដែលពួកគេមិនគួរបន្ថែមបន្ទុកទៅលើប្រទេសកំពុងអនុវត្តរេដបូកនោះទេ។ ជាពិសេស វាមិនគួរបន្ថែមបន្ទុកទៅលើការវាស់វែង ការរាយការណ៍ និងការផ្ទៀងផ្ទាត់ (MRV) នោះទេ។ ផលប្រយោជន៍មិនមែនជាកាបូន គួរត្រូវបានកំណត់ និងគាំទ្រនៅថ្នាក់ជាតិ ហើយមិនចាំបាច់ឲ្យមានច្បាប់អន្តរជាតិនោះទេ។ ក្នុងពេលជាមួយគ្នានេះ ក្រុមបណ្តាប្រទេសមួយក្រុមទៀត គឺចង់ឲ្យ UNFCCC បង្ហាញពីការគាំទ្រហិរញ្ញប្បទានអន្តរជាតិជាពិសេសសម្រាប់ផលប្រយោជន៍មិនមែនជាកាបូន។ របៀបវារៈនេះនឹងត្រូវបានពិភាក្សានៅ SBSTA42 នៅទីក្រុងប៊ែរឡាំង ឆ្នាំ២០១៥។

**រវាង បច្ចុប្បន្ន និង SBSTA41 នៅទីក្រុងលីម៉ា**

ដល់ត្រឹមថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៤ ប្រទេសទាំងឡាយនឹងត្រូវបានអញ្ជើញឲ្យបញ្ជូនទស្សនៈរបស់ពួកគេ អំពីបទពិសោធន៍ និងមេរៀនដែលទទួលបានមកពីការរៀបចំប្រព័ន្ធសម្រាប់ផ្តល់ព័ត៌មាន អំពីថាតើគោលការណ៍ការពារសុវត្ថិភាព កំពុងត្រូវបានដោះស្រាយ និងគោរពដោយរបៀបណា។ ការដាក់បញ្ជូននេះ នឹងត្រូវបានពិចារណានៅកិច្ចប្រជុំ SBSTA41។

យោងតាមការសម្រេចចិត្តពីកិច្ចប្រជុំលើកទី១៩ នៅទីក្រុងវ៉ាស័រ (Warsaw) លេខាធិការដ្ឋាន UNFCCC នឹងរៀបចំកិច្ចប្រជុំក្រុមអ្នកជំនាញការមួយ អំពីប្រព័ន្ធបណ្តុំ និងចែកចាយព័ត៌មានតាមអ៊ិនធឺណេត (the information hub of the web platform) នៅក្នុងគេហទំព័ររបស់ UNFCCC ដែលប្រទេសទាំងអស់បានធ្វើការសម្រេចចិត្តបង្កើតឡើង។ នេះទំនងនឹងផ្តោតទៅលើសំណួរទាក់ទងនឹង ថាតើព័ត៌មាននឹងត្រូវបានបង្ហាញយ៉ាងដូចម្តេច តើវានឹងត្រូវបានដាក់បញ្ជូនដោយរបៀបណាជាដើម។ កិច្ចប្រជុំត្រូវបានរំពឹងថានឹងធ្វើឡើងនៅ ខែកញ្ញា ឆ្នាំ២០១៤។

# កម្រងសិក្ខាសាលាស្តីពី ការប្រែប្រួលអាកាសធាតុ អភិបាលកិច្ចព្រៃឈើ និងរេដបូកនៅប្រទេសកម្ពុជា




ដើម្បីចូលរួមចំណែកក្នុងកិច្ចខិតខំប្រឹងប្រែងបង្កើនការយល់ដឹងអំពីរេដបូក ដេប៉ាតឺម៉ង់សិក្សាអន្តរជាតិនៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ (RUPP) និងបណ្តាញអង្គការសង្គមស៊ីវិល-រេដបូកកម្ពុជា (CSO-REDD+) បានរៀបចំសិក្ខាសាលាចំនួន ១០លើក ស្តីពីការប្រែប្រួលអាកាសធាតុ អភិបាលកិច្ចព្រៃឈើ និងរេដបូក នៅចន្លោះពីថ្ងៃទី១៥ខែកុម្ភៈដល់ថ្ងៃទី២១ខែមិថុនាឆ្នាំ២០១៤។សិក្ខាលាលាមួយលើកៗ បានទាក់ទាញនិស្សិតប្រមាណ៣៥នាក់ ពីដេប៉ាតឺម៉ង់ផ្សេងៗនៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ និងសាកលវិទ្យាល័យភូមិន្ទកសិកម្ម។ វេទិកានៃអង្គការមិនមែនរដ្ឋាភិបាលស្តីពីកម្ពុជា បានផ្តល់ការគាំទ្រថវិកាលើសកម្មភាពការងារនេះ។

គោលដៅរបស់សិក្ខាសាលាគឺ៖ (១) ណែនាំនិស្សិតពីការរៀបចំ និងការអនុវត្តរេដបូកនៅកម្ពុជា (២) លើកទឹកចិត្តនិស្សិតឲ្យស្វែងយល់ពីអភិបាលកិច្ចព្រៃឈើរេដបូកនិងបញ្ហាការប្រែប្រួលអាកាសធាតុនានា ដែលអាចជាប្រធានបទសំខាន់ៗ សម្រាប់និក្ខេបបទរបស់ពួកគេ (៣) ណែនាំនិស្សិតឲ្យស្គាល់ពីស្ថាប័នផ្សេងៗដែលធ្វើការអនុវត្តរេដបូកនៅប្រទេសកម្ពុជា (៤) បង្កើតបណ្តាញការងារមួយរវាងសាកលវិទ្យាល័យឈានមុខពីរជាមួយនឹងស្ថាប័ននានា ដែលបានចូលរួម ក្នុងការស្វែងយល់ដឹងអំពីរេដបូកក្នុងប្រទេសកម្ពុជា និង (៥) រៀបចំនិស្សិតសម្រាប់ទទួលបានការចុះកម្មសិក្សាឬអាជីពសំខាន់ៗតាមស្ថាប័ន ដែលកំពុងធ្វើការអនុវត្តលើរេដបូកនៅកម្ពុជា។

វាគ្មិន រួមមានតំណាងអញ្ជើញមកពីស្ថាប័នរដ្ឋាភិបាល និងអង្គការមិនមែនរដ្ឋាភិបាលដូចជា៖ រដ្ឋបាលព្រៃឈើលេខាធិការដ្ឋានរេដបូកកម្ពុជា កម្មវិធីអភិវឌ្ឍសហប្រជាជាតិ(UNDP) សាកលវិទ្យាល័យភូមិន្ទភ្នំពេញ អង្គការអភិរក្សសត្វព្រៃ(WCS) វេទិកានៃអង្គការមិនមែនរដ្ឋាភិបាលស្តីពីកម្ពុជា(NGOF) អង្គការរុក្ខជាតិនិងសត្វព្រៃអន្តរជាតិ(FFI) កម្មវិធីផ្លាស់ប្តូរអនុផលព្រៃឈើ(NTFP-EP) និងវិទ្យាស្ថានគ្រប់គ្រងបូព៌ាបច្ឆិម(EWMI)។

បើយោងតាមការវាយតម្លៃ ដែលបានធ្វើឡើងនៅចុងបញ្ចប់នៃសិក្ខាសាលាចុងក្រោយ បានបង្ហាញថា កម្រងសិក្ខាសាលានេះគឺបានទទួលជោគជ័យ។ និស្សិតមួយរូបបានសរសេរថា៖ "បន្ទាប់ពីចូលរួមសិក្ខាសាលា ខ្ញុំបានរៀនសូត្របានយ៉ាងច្រើនអំពីកម្មវិធី និងសកម្មភាពរេដបូក និងអំពីរបៀបដែលសហគមន៍អន្តរជាតិកំពុងធ្វើការងារលើផ្នែកនេះ។ ជាពិសេស សិក្ខាសាលាទាំងនេះបានណែនាំឲ្យស្គាល់អ្នកពាក់ព័ន្ធនានា ដែលចូលរួមធ្វើការអនុវត្តពាក់ព័ន្ធនឹងការងារអភិបាលកិច្ចព្រៃឈើនៅកម្ពុជា។ ខ្ញុំសូមអរគុណចំពោះការផ្តល់ឱកាស ដើម្បីធ្វើការសាកសួរផ្ទាល់ជាមួយវាគ្មិន"។

ពេលដែលសួរពួកគេ ថាតើពួកគេចាប់អារម្មណ៍ផ្នែកទី២ នៃកម្រងសិក្ខាសាលាទៀតដែរឬទេ និស្សិតទាំងអស់បានគាំទ្រ។ ពួកគេក៏បានសំណូមពរដែរថា សម្រាប់កម្រងសិក្ខាសាលាបន្តបន្ទាប់ទៀតគួរផ្តោតទៅលើប្រធានបទ ដែលទាក់ទងនឹងការវិវឌ្ឍនៃអាកាសធាតុ ដែលស្របនឹងស្ថានភាពក្នុងប្រទេសកម្ពុជា។

*សម្រាប់ព័ត៌មានលម្អិតសូមទាក់ទង លោក ងួន ភក្តី ពីសាកលវិទ្យាល័យភូមិន្ទភ្នំពេញ និងកញ្ញា តេង រិទ្ធីនី ពីអង្គការ NGOF*

## បច្ចុប្បន្នភាពនៃគេហទំព័ររបស់រេដបូកកម្ពុជា

សម្រាប់ព័ត៌មានបន្ថែម សូមចូលទៅគេហទំព័ររេដបូកកម្ពុជា៖ www.cambodia-redd.org ។ ព័ត៌មានដែលបានដាក់បញ្ចូលថ្មីៗ៖

- របាយការណ៍បច្ចេកទេសពីក្រុមការងារពាក់ព័ន្ធ
- ឯកសារកិច្ចប្រជុំក្រុមប្រឹក្សាប្រតិបត្តិ (PEB) លើកទីប្រាំបី

ព័ត៌មានលម្អិតមានជូនពិស្តារនៅក្នុង៖
**http://www.cambodia-redd.org/category/document-centre**

## ព័ត៌មានទំនាក់ទំនងលេខាធិការដ្ឋានរេដបូកកម្ពុជា

**លោក យុន វឌ្ឍនា**
ប្រធានលេខាធិការដ្ឋានក្រុមការងាររេដបូក
#៤០ មហាវិថីព្រះនរោត្តម សង្កាត់ផ្សារកណ្តាល ភ្នំពេញ កម្ពុជា
លេខទូរស័ព្ទ៖ (+៨៥៥) ២៣ ២២៤ ២៥១
អ៊ីម៉ែល៖ redd.secretariat@cambodia-redd.org
គេហទំព័រ៖ www.cambodia-redd.org